# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**លេខ :** ០៥៩/២១ ក.ប/ស.ជ.ណ.ម.ក

# សេចក្តីជូនដំណឹង
## ស្តីពី
## ការផ្អាកការធ្វើដំណើរចូលប្រទេសជប៉ុនជាបណ្តោះអាសន្ន សម្រាប់កម្មសិក្សាការី-ពលករជំនាញកម្ពុជា

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនដល់សមាគមទីភ្នាក់ងារជ្រើសរើសឯកជន ទីភ្នាក់ងារជ្រើសរើសឯកជន និងកម្មសិក្សាការី-ពលករជំនាញ ដែលត្រៀមចេញដំណើរទៅធ្វើកម្មសិក្សា និងធ្វើការនៅប្រទេសជប៉ុនទាំងអស់ឱ្យបានជ្រាបថា ដើម្បីបង្ការការឆ្លងរីករាលដាលនៃវីរុសកូវីដ-១៩ បំប្លែងថ្មីឈ្មោះអូមីក្រុង (Omicron) រាជរដ្ឋាភិបាលជប៉ុនបានសម្រេចផ្អាកការធ្វើដំណើរចូលប្រទេសជប៉ុនជាបណ្តោះអាសន្នចំពោះអ្នកដំណើរថ្មី រួមទាំងកម្មសិក្សាការី-ពលករជំនាញកម្ពុជាដែលត្រៀមចេញដំណើរទៅធ្វើការនៅប្រទេសជប៉ុនផងដែរ សម្រាប់រយៈពេល ០១ខែ គិតចាប់ពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ នេះតទៅ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ទីភ្នាក់ងារជ្រើសរើសឯកជន និងកម្មសិក្សាការី-ពលករជំនាញដែលត្រៀមចេញទៅធ្វើកម្មសិក្សា និងធ្វើការនៅប្រទេសជប៉ុនទាំងអស់ ជ្រាបជាព័ត៌មានតាមការគួរ។

ថ្ងៃព្រហស្បតិ៍ ១៣រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២ ខែ ១២ ឆ្នាំ២០២១
**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**ចម្លងជូន**
- សមាគមទីភ្នាក់ងារជ្រើសរើសពលករកម្ពុជា(ACRA)
- សមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជា(MAC)
- ទីភ្នាក់ងារជ្រើសរើសឯកជនទាំងអស់
  "ដើម្បីជួយផ្សព្វផ្សាយ និងសហការ"
- ឯកសារ-កាលប្បវត្តិ